ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
លេខ: ០១១/ប្រ.ក...អ.ជ.ប.គ.ញ
០៩

# ប្រកាស
## ស្តីពី
## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ
## នាយកដ្ឋាន ផែនការ និងបណ្តុះបណ្តាល
## នៃ អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០៩០៨/១០៥៤ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៧៤ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ សន/រកត/០៩៩៥/៦៥ ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញអនុក្រឹត្យលេខ ១៣ អន.ក្រ.បក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- តាមសំណើរបស់អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## សំ រេ ច

**ប្រការ១** : ប្រកាសនេះកំណត់តួនាទី និងរចនាសម្ព័ន្ធរបស់នាយកដ្ឋានផែនការ និងបណ្តុះបណ្តាល នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

## អំពីតួនាទី និងភារកិច្ច

**ប្រការ ២ :** នាយកដ្ឋានផែនការ និងបណ្តុះបណ្តាលមានភារកិច្ចដូចខាងក្រោម ៖

- រៀបចំយុទ្ធសាស្ត្រ និងលើកផែនការគោលក្នុងការបង្ក្រាបការដាំដុះ ការផលិត ការជួញដូរ ការនាំចេញ និងនាំចូល ការដឹកជញ្ជូននូវគ្រឿងញៀនខុសច្បាប់ ដោយសហការជាមួយ ក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។
- រៀបចំគំរោងសកម្មភាព ដើម្បីអនុវត្តបទប្បញ្ញត្តិទាំងឡាយ នៃអនុសញ្ញាទោលស្តីពីគ្រឿងញៀនឆ្នាំ១៩៦១ ដែលបានធ្វើវិសោធនកម្មដោយពិធីសារឆ្នាំ១៩៧២ អនុសញ្ញាស្តីពីសារធាតុ ដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទឆ្នាំ១៩៧១ និងអនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងការចរាចរខុសច្បាប់នូវគ្រឿងញៀន និងសារធាតុ ដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទឆ្នាំ១៩៨៨ ។
- ពិនិត្យតាមដានការអនុវត្តន៍គោលនយោបាយ និងសេចក្តីសំរេចរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។
- រៀបចំផែនការថ្នាក់ជាតិ និងគ្រប់គ្រងគំរោង ដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។
- រៀបចំ និងអនុវត្តគោលនយោបាយ ស្តីពីការបណ្តុះបណ្តាលដល់មន្ត្រី បុគ្គលិករបស់អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងក្រសួងស្ថាប័នពាក់ព័ន្ធ ។
- សហការជាមួយអង្គការជាតិ និងអន្តរជាតិ ដើម្បីយល់ដឹងពីគោលការណ៍របស់តំបន់ អនុតំបន់ និងអន្តរជាតិ ស្តីពីគ្រឿងញៀន។

## អំពីរចនាសម្ព័ន្ធ

**ប្រការ៣ :** នាយកដ្ឋានផែនការ និងបណ្តុះបណ្តាលដឹកនាំនិងគ្រប់គ្រងដោយប្រធាននាយកដ្ឋាន១រូប និងមានអនុប្រធានជាជំនួយការ។

ប្រធាននាយកដ្ឋានត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់អគ្គលេខាធិការដោយមានការយល់ព្រមពីប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ពីក្នុងចំណោមមន្ត្រី ដែលមានឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ឬនាយនគរបាលជាតិជាន់ខ្ពស់ចាប់ពីថ្នាក់ឧត្តមសេនីយ៍ត្រី ។

អនុប្រធាននាយកដ្ឋានត្រូវតែងតាំងដោយប្រកាសអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនតាមសំណើរបស់ប្រធាននាយកដ្ឋានផែនការ និងបណ្តុះបណ្តាល ដោយមានការឯកភាពពីអគ្គលេខាធិការក្នុងចំណោមមន្ត្រីដែលមានឋានន្តរស័ក្តិអនុមន្ត្រី នៃក្របខ័ណ្ឌរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ឬនាយនគរបាលជាតិជាន់ខ្ពស់ថ្នាក់វរសេនីយ៍ឯក។

**ប្រការ៤ :** ប្រធាននាយកដ្ឋាន ផែនការ និងបណ្តុះបណ្តាលត្រូវបំពេញភារកិច្ចដូចខាងក្រោមៈ

- ទទួលខុសត្រូវលើការងារដំណើរការនិងគ្រប់គ្រងនាយកដ្ឋាន និងទទួលខុសត្រូវលើកិច្ចការនានាចំពោះមុខអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ។
- រាយការណ៍ជូនអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ពីកិច្ចការនានា ដែលទាក់ទងទៅនឹងការងារដំណើរការ និងគ្រប់គ្រងនាយកដ្ឋាន ។
- លើកសំណើអំពីការតែងតាំង ការដំឡើងឋានន្តរស័ក្តិ ឬផ្ទេរមន្ត្រីរាជការក្រោមឱវាទរបស់នាយកដ្ឋាន ។
- ចុះហត្ថលេខាលើគ្រប់ឯកសារដែលទាក់ទងទៅនឹងការងាររបស់នាយកដ្ឋាន ។
- មានសិទ្ធិធ្វើប្រតិភូកម្មអំណាចចុះហត្ថលេខា ដែលទាក់ទងកិច្ចការនាយកដ្ឋាន ដល់អនុប្រធាននាយកដ្ឋាន ។

**ប្រការ៥ :** អនុប្រធាននាយកដ្ឋានផែនការ និងបណ្តុះបណ្តាលត្រូវបំពេញភារកិច្ចដូចខាងក្រោមៈ

- ទទួលខុសត្រូវចំពោះមុខប្រធាននាយកដ្ឋានចំពោះកិច្ចការនានាដែលប្រគល់ឱ្យ ។
- ត្រូវរាយការណ៍ជូនប្រធាននាយកដ្ឋាន អំពីកិច្ចការនានា ដែលស្ថិតក្រោមការទទួលខុសត្រូវ ឬសមត្ថកិច្ចរបស់ខ្លួន ។
- មានសិទ្ធិចុះហត្ថលេខាលើឯកសារ ដែលទាក់ទងទៅនឹងកិច្ចការរដ្ឋបាលក្រោមការធ្វើប្រតិភូកម្មពីប្រធាននាយកដ្ឋាន។

## អំពីរចនាសម្ព័ន្ធ

**ប្រការ៦ :** នាយកដ្ឋាន ផែនការ និងបណ្តុះបណ្តាល មាន ០៤ការិយាល័យជាសេនាធិការ :

- ការិយាល័យរដ្ឋបាល
- ការិយាល័យ ផែនការទូទៅ
- ការិយាល័យបណ្តុះបណ្តាល និងសហប្រតិបត្តិការអន្តរជាតិ
- ការិយាល័យគ្រប់គ្រងគំរោង

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានការិយាល័យមួយរូប អមដោយអនុប្រធានការិយាល័យយ៉ាងច្រើនចំនួន៣រូប ។

ប្រធានការិយាល័យ ត្រូវតែងតាំងដោយប្រកាសរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនតាមសំណើប្រធាននាយកដ្ឋានផែនការ និងបណ្តុះបណ្តាលដោយមានការឯកភាពពីអគ្គលេខាធិការពីក្នុងចំណោមមន្ត្រីដែលមានឋានន្តរសក្តិនាយក្រមការនៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ឬនាយនគរបាលជាតិថ្នាក់វរសេនីយ៍ទោ ។

អនុប្រធានការិយាល័យ ត្រូវតែងតាំងដោយប្រកាសរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន តាមសំណើប្រធាននាយកដ្ឋានផែនការ និងបណ្តុះបណ្តាល ដោយមានការឯកភាព ពីអគ្គលេខាធិការ ពីក្នុងចំណោមមន្ត្រីដែលមានឋានន្តរស័ក្តិក្រមការដើមខ្សែ នៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ឬនាយនគរបាលជាតិថ្នាក់វរសេនីយ៍ត្រី ។

អង្គការលេខរបស់នាយកដ្ឋានផែនការ និងបណ្តុះបណ្តាលមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់ ។

## អំពីភារកិច្ចរបស់ការិយាល័យ

**ប្រការ៧ :** ការិយាល័យ រដ្ឋបាល មានភារកិច្ច ដូចខាងក្រោមៈ

- ធ្វើតារាងរបៀប រដ្ឋបាល គ្រប់គ្រង និងចរាចរឯកសារផ្សេងៗរបស់នាយកដ្ឋាន
- សរុប និងធ្វើរបាយការណ៍សកម្មភាពការងាររបស់នាយកដ្ឋាន
- គ្រប់គ្រងមន្ត្រី បុគ្គលិករបស់នាយកដ្ឋាន
- រៀបចំកម្មវិធីប្រជុំរបស់នាយកដ្ឋាន
- អនុវត្តគោលនយោបាយ របបជូនមន្ត្រីរាជការក្នុងនាយកដ្ឋាន តាមការកំណត់របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- គ្រប់គ្រងចលនវត្ថុ និងអចលនវត្ថុ សំភារៈរបស់នាយកដ្ឋាន
- លើកគំរោងចំណាយថវិកា សំភារៈ ប្រេងឥន្ធនៈ សំរាប់បំរើសកម្មភាពរបស់នាយកដ្ឋាន លើកគំរោងស្នើសុំថវិកា អំពីការងារបណ្តុះបណ្តាល និងការងារកាត់បន្ថយការប្រើបំពានគ្រឿងញៀន។

**ប្រការ៨ :** ការិយាល័យ ផែនការទូទៅ មានភារកិច្ចដូចខាងក្រោមៈ

- រៀបចំយុទ្ធសាស្ត្រ និងលើកផែនការគោលក្នុងការបង្ក្រាបការដាំដុះ ការផលិត ការជួញដូរ ការនាំចេញ និងនាំចូល ការដឹកជញ្ជូននូវគ្រឿងញៀនខុសច្បាប់ ដោយសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀត ។
- រៀបចំគំរោងសកម្មភាព ដើម្បីអនុវត្តបទប្បញ្ញត្តិទាំងឡាយ នៃអនុសញ្ញាទោលស្តីពីគ្រឿងញៀនឆ្នាំ ១៩៦១ ដែលបានធ្វើវិសោធនកម្មដោយពិធីសារឆ្នាំ១៩៧២ អនុសញ្ញាស្តីពីសារធាតុដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទឆ្នាំ១៩៧១ និងអនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងការចរាចរខុសច្បាប់នូវគ្រឿងញៀន និង សារធាតុដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ឆ្នាំ ១៩៨៨ ។
- ពិនិត្យតាមដានការអនុវត្តន៏គោលនយោបាយ ផែនការ និងសេចក្តីសំរេចនានារបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។ វិភាគរកចំណុចខ្លាំង និងការខ្វះខាត ដើម្បីវាយតំលៃហើយជូន

យោបល់ទៅថ្នាក់ដឹកនាំរបស់អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដើម្បីមានវិធានការឬលើកផែនការឡើងវិញ ។

- រៀបចំផែនការថ្នាក់ជាតិ និងផែនការសកម្មភាពប្រចាំឆ្នាំ ដោយសហការជាមួយបណ្តាក្រសួង ស្ថាប័ន អង្គភាព និងនាយកដ្ឋាននានាដែលពាក់ព័ន្ធ ។
- ទំនាក់ទំនងសម្របសម្រួលជាមួយអ្នកឯកទេស ឬជំនាញការ ដើម្បីសិក្សាស្រាវជ្រាវផែនការរបស់តំបន់ អនុតំបន់ អង្គការជាតិ អន្តរជាតិក្នុងគោលបំណងកសាងផែនការសំរាប់អនុវត្តឱ្យបានសមស្រប
- សហការជាមួយក្រសួង-ស្ថាប័ននានា អង្គការក្រៅរដ្ឋាភិបាលដើម្បីសិក្សាស្វែងយល់អំពីបញ្ហាគ្រឿងញៀនថ្មីដែលកើតមានឡើង ។

**ប្រការ៩ :** ការិយាល័យ បណ្តុះបណ្តាល និងសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចដូចខាងក្រោម:

- រៀបចំ និងអនុវត្តនយោបាយ ស្តីពីការបណ្តុះបណ្តាលដល់មន្ត្រីបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ។
- សហការជាមួយអង្គការជាតិ និងអន្តរជាតិ ដើម្បីយល់ដឹងពីគោលការណ៍របស់តំបន់ អនុតំបន់ និងអន្តរជាតិស្តីពីគ្រឿងញៀន ។
- សហការជាមួយនាយកដ្ឋាន អង្គភាពពាក់ព័ន្ធ ដើម្បីក្តាប់បានពីបណ្តាវគ្គបណ្តុះបណ្តាលទាំងផ្នែកពង្រឹងសមត្ថភាពជំនាញទាក់ទងទៅនឹងការបង្ក្រាបការប្រើបំពានគ្រឿងញៀន ដើម្បីលើកផែនការបណ្តុះបណ្តាលបន្ត ។
- សហការជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ នាយកដ្ឋាន អង្គការជាតិ អន្តរជាតិតំបន់ អនុតំបន់ សិក្សាស្រាវជ្រាវស្វែងយល់អំពីការរីករាលដាលថ្មីនៃបញ្ហាគ្រឿងញៀន ដើម្បីរៀបចំផែនការបណ្តុះ-បណ្តាល ឬផ្សព្វផ្សាយបន្តក្នុងគោលបំណងផ្ទេរចំណេះដឹង និងផ្តល់បទពិសោធន៍ឱ្យគ្នាទៅវិញទៅមក

**ប្រការ១០:** ការិយាល័យគ្រប់គ្រងគំរោង មានភារកិច្ចដូចខាងក្រោម:

- សហការជាមួយបណ្តាក្រសួង-ស្ថាប័ន នាយកដ្ឋាន អង្គការជាតិ អន្តរជាតិនានា ដើម្បីស្វែងយល់អំពីចំនួន និងសកម្មភាពគំរោងពាក់ព័ន្ធនឹងគ្រឿងញៀនដែលកំពុងអនុវត្ត ឬគំរោងថ្មី ដែលត្រូវចាប់ផ្តើមអនុវត្តដើម្បីបំរើឱ្យការរៀបចំកសាងផែនការ ។
- សិក្សាអំពីតំរូវការនិងលើកគំរោងថវិកាសម្រាប់អនុវត្តផែនការជាតិ និងសំរាប់ផែនការសកម្មភាពរបស់ឆ្នាំនីមួយៗ ។

**ប្រការ១១:** រាល់ប្រកាស ដីកា និងលិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១២:** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គស្នងការ នៃអគ្គស្នងការដ្ឋាន នគរបាលជាតិ អគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សានីតិកម្ម ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង ប្រធាននាយកដ្ឋាន អ.ជ.ប.គ.ញ និងអង្គភាពពាក់ព័ន្ធត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែ មីនា ឆ្នាំ២០០៩*

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

**ស ខេង**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- សមាជិកអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

( *ដើម្បីជូនជ្រាប* ) ។

- ដូចប្រការ១២ ( ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ

# រចនាសម្ព័ន្ធ
# នាយកដ្ឋានផែនការ និងបណ្តុះបណ្តាល

